# គណបក្ស សម រង្ស៊ី

SAM RAINSY PARTY
PARTI SAM RAINSY
សីលធម៌ សច្ចធម៌ យុត្តិធម៌

លេខ :....១១១....ស.ណ.ន.គសរ
០៧/០៧

## សេចក្តីណែនាំ
## ស្តីពី
## នីតិវិធី និងបែបបទ នៃការបោះឆ្នោតជ្រើសតាំង
## បេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស

_យោងសេចក្តីសំរេចនៃកិច្ចប្រជុំគណៈកម្មាធិការនាយកគណបក្ស ថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ នៃការធ្វើកំណែទំរង់រចនាសម្ព័ន្ធគណបក្សថ្នាក់ជាតិឲ្យស្របទៅនឹងកំណែទំរង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋាន

_យោងសេចក្តីសំរេចនៃកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០០៧ ស្តីពីការកំណត់ចំនួនបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្សនៅក្នុងអាណត្តិថ្មី ដែលត្រូវជ្រើសតាំងដោយតំណាងគណបក្សមូលដ្ឋាន តំណាងឲ្យគណបក្សខេត្ត-ក្រុង

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស សូមធ្វើការណែនាំ អំពីនីតិវិធី និងបែបបទនៃការបោះឆ្នោតជ្រើសតាំងបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស តំណាងគណបក្សខេត្ត-ក្រុង ដូចតទៅ :

### I_លក្ខខណ្ឌនៃការឈរឈ្មោះជាបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយក

ដើម្បីមានសិទ្ធិឈរឈ្មោះជាបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយក សមាជិកគណបក្សគ្រប់រូបត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម :

_អតីតសមាជិកគណៈកម្មាធិការនាយកគណបក្ស ដែលបានបង់ភាគទានទៀងទាត់ជូនគណបក្ស

_សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលបានចូលរួមយ៉ាងសកម្ម និងជាក់ស្តែង (ទាំងកម្លាំងកាយ ស្មារតី និងថវិកា) ក្នុងការងារកំណែទម្រង់រចនាសម្ព័ន្ធគណបក្ស ការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ-សង្កាត់អាណត្តិទី២ និងជួយទ្រទ្រង់ដំណើរការទីស្នាក់ការគណបក្សខេត្ត-ក្រុង (បានបង់ភាគទានទៀងទាត់ជូនក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង)

_មានចំណេះដឹងទូលំទូលាយអំពីសង្គម និងនយោបាយ

_ធានារ៉ាប់រងការចំណាយ សំរាប់ការរៀបចំការបោះឆ្នោត ។

សមាជិកគណបក្សរូបណា ដែលមានបំណងឈរឈ្មោះជាបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយកតំណាងគណបក្សខេត្ត-ក្រុងណាមួយ ត្រូវដាក់ពាក្យសុំឈរឈ្មោះមកគណៈកម្មាធិការ



ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org

អចិន្ត្រៃយ៍គណបក្ស តាមរយៈអគ្គលេខាធិការគណបក្ស យ៉ាងតិច១៥ថ្ងៃមុនការបោះឆ្នោត ។ គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស ត្រូវពិនិត្យ និងសំរេចលើពាក្យសុំនេះ យ៉ាងតិច៥ថ្ងៃមុនថ្ងៃបោះឆ្នោត ។ ទំរង់បែបបទនៃពាក្យសុំឈរឈ្មោះជាបេក្ខភាព នៃបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស កំណត់ដោយអគ្គលេខាធិការគណបក្ស ។

## II_នីតិវិធីនៃការបោះឆ្នោតជ្រើសតាំងបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយក

សមាជិកក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុង ដែលទទួលស្គាល់ដោយប្រធានគណបក្ស សមាជិកក្រុមប្រឹក្សាគណបក្សស្រុក-ខណ្ឌ និងប្រធានក្រុមប្រឹក្សាគណបក្សឃុំ-សង្កាត់ នៃខេត្ត-ក្រុងសាមី ដែលទទួលស្គាល់ដោយអគ្គលេខាធិការគណបក្ស មានសិទ្ធិបោះឆ្នោតជ្រើសតាំងបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស ។ អគ្គលេខាធិការគណបក្សទទួលភារកិច្ចធ្វើលិខិតអញ្ជើញដល់អ្នកមានសិទ្ធិបោះឆ្នោត អោយមកចូលរួមប្រជុំបោះឆ្នោតជ្រើសតាំងបេក្ខភាពនៃបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស ។

ដើម្បីឲ្យការបោះឆ្នោតអាចប្រព្រឹត្តទៅបាន ចាំបាច់ត្រូវមានកូរ៉ុម៦ភាគ១០ នៃអ្នកមានសិទ្ធិបោះឆ្នោត ។ ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតត្រូវបង្ហាញបញ្ជីរាយនាមបេក្ខភាពនៃបេក្ខជនឈរឈ្មោះជាសមាជិកគណៈកម្មាធិការនាយក ដល់អ្នកបោះឆ្នោត ។ អ្នកបោះឆ្នោតមានសិទ្ធិគូសយកនូវបេក្ខភាពដែលខ្លួនពេញចិត្ត តាមចំនួនដែលប្រធានគណៈកម្មការបានកំណត់ ។ ឈ្មោះដែលបានទទួលការគាំទ្រនៅលើបញ្ជីរាយនាមបេក្ខភាព មិនត្រូវមានចំនួនលើសពីចំនួនបេក្ខជនសមាជិកគណៈកម្មាធិការនាយកដែលត្រូវជ្រើសតាំង (បានកំណត់) នោះទេ ។ បើលើស សន្លឹកឆ្នោតនោះត្រូវទុកជាមោឃៈ ។ បេក្ខភាពនៃបេក្ខជនណាដែលបានទទួលសំលេងគាំទ្រច្រើនជាងគេពីការបោះឆ្នោត នឹងត្រូវជ្រើសតាំងជាបេក្ខជនសមាជិកគណៈកម្មាធិការនាយកគណបក្ស តាមលំដាប់លំដោយនៃចំនួនសំលេងដែលបេក្ខភាពម្នាក់ៗបានទទួល ។ ក្នុងករណីបេក្ខភាពជាប់ឆ្នោតជាបេក្ខជនសមាជិកគណៈកម្មាធិការនាយកមានចំនួនលើសចំនួនដែលបានកំណត់ ដោយសារសំលេងឆ្នោតស្មើគ្នា បេក្ខភាពស្ត្រីត្រូវជ្រើសជាអាទិភាព ។ បើបេក្ខភាពទាំងអស់មានភេទដូចគ្នា គណៈកម្មការរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតបន្ត ។

បើលទ្ធផលនៃការបោះឆ្នោតនៅជុំទី១ មិនអាចជ្រើសតាំងបេក្ខជនសមាជិកគណៈកម្មាធិការនាយកបានគ្រប់ចំនួន គណៈកម្មការរៀបចំការបោះឆ្នោតត្រូវរៀបចំការបោះឆ្នោតបន្ត តាមនីតិវិធីដូចខាងលើ ដោយយកបេក្ខភាពយ៉ាងច្រើន២ដងនៃចំនួនបេក្ខភាពដែលត្រូវជ្រើសតាំងបន្ត ។

## III_ការគ្រប់គ្រងការបោះឆ្នោត

ការរៀបចំការបោះឆ្នោតជ្រើសតាំងបេក្ខជនសមាជិកគណៈកម្មាធិការនាយក តំណាងគណបក្ស ខេត្ត-ក្រុង ជាសមត្ថកិច្ចរបស់គណៈកម្មការមួយ ដែលតែងតាំងដោយប្រធានគណបក្ស ។ ប្រធាន

អនុប្រធាន និងសមាជិក នៃគណៈកម្មការរៀបចំការបោះឆ្នោត គឺជាសមាភាពដែលមិនមែនជាបេក្ខភាពឈរឈ្មោះប្រកួតប្រជែងយកតំណែងបេក្ខជនសមាជិកគណៈកម្មាធិការនាយក ។

គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធានាដំណើរការ និងការប្រព្រឹត្តទៅ នៃការរៀបចំការបោះឆ្នោតឲ្យមានតម្លាភាព និងយុត្តិធម៌ ស្របតាមបទប្បញ្ញត្តិជាធរមានរបស់គណបក្ស ។

## IV_ថវិកាសំរាប់ការរៀបចំការបោះឆ្នោត

ថវិកាសំរាប់ចំណាយក្នុងការរៀបចំការបោះឆ្នោត ជ្រើសតាំងបេក្ខជនសមាជិកគណៈកម្មាធិការនាយក ត្រូវធានារ៉ាប់រងដោយបេក្ខជនឈរឈ្មោះជាសមាជិកគណៈកម្មាធិការនាយក ដោយចែករំលែកភាគចំណាយស្មើគ្នា នៃចំណាយសរុបក្នុងការរៀបចំការបោះឆ្នោត ។

## V_ទោសប្បញ្ញត្តិ

គណៈកម្មាធិការអចិន្ត្រៃយ៍គណបក្ស នឹងត្រូវព្រមាន ឬដកហូតសិទ្ធិក្នុងការបោះឆ្នោត និងសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត ជាសមាជិកគណៈកម្មាធិការនាយក ដល់បេក្ខជនគ្រប់រូប ឬអ្នកគាំទ្របេក្ខជនរូបណាក៏ដោយ ដែលបានប្រព្រឹត្តនូវកំហុសដូចខាងក្រោម :

_ប្រើប្រាស់លុយកាក់ សំភារៈ ឬធ្វើពិធីជប់លៀងដល់អ្នកបោះឆ្នោត ឬ

_សន្យាផ្តល់នូវមុខតំណែងដើម្បីទិញទឹកចិត្តអ្នកបោះឆ្នោត ឬ

_គំរាមកំហែង សម្លុត ឬបំភិតបំភ័យអ្នកបោះឆ្នោត ឬ

_ទទួលសំណូកសូកប៉ាន់ ដើម្បីគៀងគររកសម្លេងឆ្នោតឲ្យបេក្ខជនណាមួយ ឬ

_បំផ្លាញលទ្ធផលនៃការបោះឆ្នោត ។

សេចក្តីណែនាំនេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី...[illegible] ខែកក្កដា ឆ្នាំ២០០៧

ប្រធានគណបក្ស

សម រង្ស៊ី

# គណបក្ស សម រង្ស៊ី

**SAM RAINSY PARTY**
**PARTI SAM RAINSY**

**សីលធម៌ សច្ចធម៌ យុត្តិធម៌**

រូបថតទំហំ
៤ x ៦cm

## ព័ត៌មានសង្ខេបផ្ទាល់ខ្លួន

(សំរាប់បេក្ខជនសមាជិកគណៈកម្មាធិការនាយកតំណាងគណបក្សខេត្ត-ក្រុង)

១_នាម និង គោត្តនាម.................................................................................. ភេទ............................

_ឈ្មោះជាអក្សរឡាតាំង.....................................................................................................................

២_ថ្ងៃខែឆ្នាំកំណើត......................... ទីកន្លែងកំណើតនៅភូមិ..................... ឃុំ-សង្កាត់................

ស្រុក-ខណ្ឌ................................................ ខេត្ត-ក្រុង.....................................................

៣_អាស័យដ្ឋានបច្ចុប្បន្នផ្ទះលេខ.......... ផ្លូវ............. ភូមិ...................... ឃុំ-សង្កាត់.......................

ស្រុក-ខណ្ឌ................................................ ខេត្ត-ក្រុង.....................................................

៤_មុខរបរ.................................................................................................................................

៥_កំរិតវប្បធម៌..........................................................................................................................

៦_តួនាទីបច្ចុប្បន្ននៅក្នុងគណបក្ស......................................................................................................

៧_ថវិកាដែលបានបង់ចូលបេឡាគណបក្ស (សំរាប់អតីតសមាជិកគណៈកម្មាធិការនាយក) ចាប់ពីឆ្នាំ២០០៤ :............................................................................................................

៨_ថវិកាដែលបានបង់ចូលបេឡាក្រុមប្រឹក្សាគណបក្សខេត្ត-ក្រុងណាមួយ :

ក) ឆ្នាំ២០០៤.......... ខ) ឆ្នាំ២០០៥.......... គ) ឆ្នាំ២០០៦.......... ឃ) ឆ្នាំ២០០៧...........

៩_សកម្មភាពដែលបានជួយការងារគណបក្សនៅក្នុងខេត្ត-ក្រុងកន្លងមក ពីឆ្នាំ២០០៤ ដល់បច្ចុប្បន្ន :

ក) បានជួយការងារកំណែទម្រង់រចនាសម្ព័ន្ធគណបក្សមូលដ្ឋាននៅស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ណា?

.............................................................................. ជួយរបៀបណា ជាថវិកា ☐ ឬ ជាកម្លាំងចុះរៀបចំការងារ ☐ ឬទាំងថវិកា និង ទាំងកម្លាំង ☐ អ្នកណាដឹងឮ? ......................

.............................................................................................................................

ខ) បានជួយការងារបោះឆ្នោតក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី២ នៅស្រុក-ខណ្ឌ ឬឃុំ-សង្កាត់ណា?

.............................................................................. ជួយរបៀបណា ជាថវិកា ☐ ឬ ជាកម្លាំងដឹកនាំយុទ្ធនាការ ☐ ឬទាំងថវិកា និង ទាំងកម្លាំង ☐ អ្នកណាដឹងឮ? ......................

.............................................................................................................................

.............................................................................................................................

.............................................................................................................................

**បានឃើញ និង ឯកភាព** *ថ្ងៃទី............ ខែ................ ឆ្នាំ..............*

**អ្នកដឹងឮ** **ហត្ថលេខាសាមីខ្លួន**

**ទីស្នាក់ការកណ្តាល : ផ្ទះលេខ ៧១ មហាវិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា**
Headquarters : House # 71 Sothearos Road, Phnom Penh, Kingdom of Cambodia
Tel : (855-23) 217 452 / 211 336 Fax : (855-23) 217 452 / 211 336
**E-mail address :** srphq@online.com.kh, srpcabinet@online.com.kh, Website : samrainsyparty.org